BỘ TƯ PHÁP | CHÍNH PHỦ NHẬT BẢN | QUỸ PHÁT TRIỂN XÃ HỘI NHẬT BẢN | NGÂN HÀNG THẾ GIỚI

ជំនួយគតិយុត្តិស្តីពីសិទ្ធិចិញ្ចឹមកូនក្រោយពេលលែងលះ



ឆ្នាំ ២០២៥.

តើជំនួយគតិយុត្តិជាអ្វី?

ជំនួយគតិយុត្តិ គឺជាការផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកទទួលបានជំនួយគតិយុត្តិ ក្នុងរឿងក្តីជំនួយគតិយុត្តិ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជំនួយគតិយុត្តិ។

សិទ្ធិស្នើសុំដោះស្រាយការលែងលះ

- ភរិយា ស្វាមី ឬទាំងពីរនាក់ មានសិទ្ធិស្នើសុំឲ្យតុលាការដោះស្រាយការលែងលះ។
- ឪពុក ម្តាយ ឬសាច់ញាតិដទៃទៀត មានសិទ្ធិស្នើសុំឲ្យតុលាការដោះស្រាយការលែងលះ នៅពេលដែលភាគីម្ខាង (ភរិយា ឬស្វាមី) ដោយសារជំងឺវិកលចរិត ឬកើតជំងឺដទៃ ដែលមិនអាចដឹងខ្លួន ឬគ្រប់គ្រងសកម្មភាពរបស់ខ្លួនបាន ព្រមទាំងជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ដែលបង្កឡើងដោយស្វាមី ឬភរិយារបស់ខ្លួន ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់អាយុជីវិត សុខភាព និងស្មារតីរបស់ខ្លួន។
- ស្វាមីគ្មានសិទ្ធិស្នើសុំលែងលះឡើយ ក្នុងករណីភរិយាកំពុងមានផ្ទៃពោះ សម្រាលកូន ឬកំពុងចិញ្ចឹមកូនអាយុក្រោម ១២ ខែ។

មូលដ្ឋានគតិយុត្តិ៖ មាត្រា ៥១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ២០១៤

ទម្រង់នៃការលែងលះ

ការលែងលះដោយស្ម័គ្រចិត្ត៖ គឺជាករណីដែលភរិយា និងស្វាមី យល់ព្រមលែងលះទាំងសងខាង ភាគីទាំងពីរពិតជាស្ម័គ្រចិត្តលែងលះ ហើយបានព្រមព្រៀងគ្នារួចរាល់អំពីការបែងចែកទ្រព្យសម្បត្តិ ការមើលថែចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំកូន (បើមាន) ហើយកិច្ចព្រមព្រៀងនេះ ត្រូវធានាបាននូវផលប្រយោជន៍ស្របច្បាប់របស់ភរិយា និងកូន។ នៅពេលបំពេញលក្ខខណ្ឌគ្រប់គ្រាន់ តុលាការនឹងទទួលស្គាល់ការលែងលះដោយស្ម័គ្រចិត្ត។

ការលែងលះតាមសំណើរបស់ភាគីម្ខាង៖ គឺជាករណីដែលមានតែភាគីម្ខាង (ភរិយា ឬស្វាមី) ស្នើសុំឲ្យតុលាការដោះស្រាយការលែងលះ នៅពេលមានមូលដ្ឋានអំពីការដែលភរិយា ឬស្វាមី មានអំពើហិង្សាក្នុងគ្រួសារ ឬបំពានធ្ងន់ធ្ងរដល់សិទ្ធិ និងករណីយកិច្ចរបស់ភរិយា ស្វាមី ធ្វើឲ្យអាពាហ៍ពិពាហ៍ធ្លាក់ចូលក្នុងស្ថានភាពធ្ងន់ធ្ងរ ជីវភាពរួមរស់មិនអាចបន្តទៅមុខទៀតបាន គោលបំណងនៃអាពាហ៍ពិពាហ៍មិនអាចសម្រេចបាន។ ក៏ប៉ុន្តែ ស្វាមីគ្មានសិទ្ធិស្នើសុំលែងលះទេ នៅពេលភរិយាកំពុងមានផ្ទៃពោះ សម្រាលកូន ឬកំពុងចិញ្ចឹមកូនអាយុក្រោម ១២ ខែ។

(មាត្រា ៥៦ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ២០១៤)

សិទ្ធិមើលថែ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូនក្រោយពេលលែងលះ (មាត្រា ៨១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ២០១៤)

១. ក្រោយពេលលែងលះ ឪពុកម្តាយនៅតែមានសិទ្ធិ និងករណីយកិច្ចមើលថែ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូនដែលមិនទាន់គ្រប់អាយុ កូនដែលគ្រប់អាយុ តែបាត់បង់សមត្ថភាពទង្វើរដ្ឋប្បវេណី ឬគ្មានលទ្ធភាពការងារ ហើយគ្មានទ្រព្យសម្បត្តិសម្រាប់ចិញ្ចឹមខ្លួនឯង។

២. ភរិយា ស្វាមី ព្រមព្រៀងគ្នាអំពីអ្នកចិញ្ចឹមកូនផ្ទាល់ ករណីយកិច្ច និងសិទ្ធិរបស់ភាគីនីមួយៗ ក្រោយពេលលែងលះចំពោះកូន។ ក្នុងករណីមិនអាចព្រមព្រៀងគ្នាបាន នោះតុលាការនឹងសម្រេចប្រគល់កូនឲ្យភាគីម្ខាងចិញ្ចឹមផ្ទាល់ ដោយផ្អែកលើផលប្រយោជន៍គ្រប់ផ្នែករបស់កូន។ បើកូនមានអាយុ ៧ ឆ្នាំឡើងទៅ នោះត្រូវពិចារណាលើសេចក្តីប្រាថ្នារបស់កូន។

៣. កូនអាយុក្រោម ៣៦ ខែ ត្រូវប្រគល់ឲ្យម្តាយចិញ្ចឹមផ្ទាល់ លើកលែងតែករណីម្តាយគ្មានលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការមើលថែ ថែរក្សា ចិញ្ចឹមបីបាច់ និងអប់រំកូនផ្ទាល់ ឬឪពុកម្តាយមានកិច្ចព្រមព្រៀងផ្សេងទៀត ដែលសមស្របនឹងផលប្រយោជន៍របស់កូន។



សំណុំឯកសារស្នើសុំជំនួយគតិយុត្តិ រួមមាន៖

ពាក្យស្នើសុំជំនួយគតិយុត្តិ។

↓

លិខិតស្នាមបញ្ជាក់ថាជាអ្នកទទួលបានជំនួយគតិយុត្តិ ស្របតាមបទប្បញ្ញត្តិនៅក្នុងសារាចរណែនាំលេខ 08/2017/TT-BTP ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលកំណត់លម្អិតមាត្រាមួយចំនួននៃច្បាប់ស្តីពីជំនួយគតិយុត្តិ និងណែនាំអំពីលិខិតស្នាមក្នុងសកម្មភាពជំនួយគតិយុត្តិ។

↓

លិខិតស្នាម និងឯកសារនានាដែលពាក់ព័ន្ធនឹងរឿងក្តីជំនួយគតិយុត្តិ។

អង្គការអនុវត្តជំនួយគតិយុត្តិ ផ្តល់សេវាគតិយុត្តិដោយឥតគិតថ្លៃ ជូនអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលបានជំនួយគតិយុត្តិ តាមទម្រង់ដូចខាងក្រោម៖



- ការប្រឹក្សាច្បាប់



- ការចូលរួមក្នុងនីតិវិធី



- ការតំណាងក្រៅនីតិវិធី

សំណុំឯកសារស្នើសុំជំនួយគតិយុត្តិ ត្រូវផ្ញើទៅ៖

1. មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ក្រោមឱវាទមន្ទីរយុត្តិធម៌ខេត្ត និងក្រុងក្រោមឱវាទថ្នាក់កណ្តាល។
2. សាខារបស់មជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ។
3. អង្គការដែលបានចុះឈ្មោះចូលរួមជំនួយគតិយុត្តិ រួមមានអង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលបានចុះឈ្មោះចូលរួមជំនួយគតិយុត្តិជាមួយមន្ទីរយុត្តិធម៌។
4. អង្គការដែលបានចុះកិច្ចសន្យាអនុវត្តជំនួយគតិយុត្តិ រួមមានអង្គការប្រកបវិជ្ជាជីវៈមេធាវី និងអង្គការប្រឹក្សាច្បាប់ ដែលបានចុះកិច្ចសន្យាអនុវត្តជំនួយគតិយុត្តិជាមួយមន្ទីរយុត្តិធម៌។

នៅពេលត្រូវការដឹងព័ត៌មានអំពីអង្គការជំនួយគតិយុត្តិ សូមទាក់ទង៖

នាយកដ្ឋានផ្សព្វផ្សាយ អប់រំច្បាប់ និងជំនួយគតិយុត្តិ ក្រសួងយុត្តិធម៌៖

អាសយដ្ឋាន៖ លេខ 58-60 ផ្លូវ Trần Phú សង្កាត់ Ba Đình ក្រុងហាណូយ។

ទូរស័ព្ទមកកាន់ខ្សែទូរស័ព្ទទាន់ហេតុការណ៍លេខ៖ **18001233**

ឬទាក់ទងដោយផ្ទាល់ទៅមជ្ឈមណ្ឌលជំនួយគតិយុត្តិរបស់រដ្ឋ ខេត្ត/ក្រុងនៃទីលំនៅ។